ក្នុងរយៈពេលបំពេញការងារក្នុងឧត្តមក្រុមនេះ ត្រូវបានគិតអតីតភាពសំរាប់ឡើងឋានន្តរស័ក្តិ ឬ ថ្នាក់ និងអតីតភាពសំរាប់ទទួលសោធននិវត្តន៍ ។

មាត្រា១២ .- មន្ត្រីដែលបំរើការងារក្នុងឧត្តមក្រុមរបស់ក្រសួង ស្ថាប័ន ដែលពីមុន ពុំស្ថិតនៅក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ក្រសួងស្ថាប័នសាមីត្រូវផ្តល់បៀវត្សជូនជាមន្ត្រីជាប់កិច្ចសន្យា ។ ទឹកប្រាក់នេះអាស្រ័យដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ជាអ្នកកំណត់ ។

មាត្រា ១៣ .-បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៤ .-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង សាមីជនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយបានសំរេច ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

**អនុក្រឹត្យ លេខ ៥១ អនក្រ.បក**

**ស្តីពីការ បង្កើតឧត្តមក្រុមប្រឹក្សា កំណែទំរង់រដ្ឋបាល**

* * *

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើត ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

-តាមសំណើរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

## សំរេច

### ជំពូក ១

### បទបញ្ញត្តិទូទៅ

មាត្រា ១ .- ត្រូវបានបង្កើត ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល សំរាប់ជំនួយការ ក្នុងការប្រតិបត្តិបេសកកម្ម របស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ក្នុងវិស័យកំណែទំរង់រដ្ឋបាល ។ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល មានទីតាំងស្ថិតនៅ ទីស្តីការគណៈរដ្ឋមន្ត្រី ។

### ជំពូក ២

### បេសកកម្ម និង សមាសភាព

មាត្រា ២ .- ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល មានបេសកកម្ម ផ្តួចផ្តើម ជំរុញ ដាក់អោយដំណើរការ និងតាមដានការអនុវត្តនីនយោបាយ និងកម្មវិធីកំណែទំរង់រដ្ឋបាល ស្របតាមការតំរង់ទិស របស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

មាត្រា ៣ .- ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល មានមុខងារ និងភារកិច្ចដូចតទៅ :

១ -ផ្តួចផ្តើម និងលើកសំណើជូនឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ នូវគំរោងផែនការកម្មវិធីការងារ និង យុទ្ធសាស្ត្រសំរាប់ធ្វើអោយសំរេចគោលដៅទាំងឡាយនៃកំណែទំរង់រដ្ឋបាល ។

២ -អនុវត្តសេចក្តីណែនាំ ដែលទទួលបានពីឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ក្នុងការដាក់អោយដំណើរការយុទ្ធសាស្ត្រ និងកម្មវិធីកំណែទំរង់រដ្ឋបាល ។

៣ -ចេញសេចក្តីសំរេច និងសេចក្តីណែនាំចាំបាច់ដល់គ្រប់ក្រសួង-ស្ថាប័ន ក្នុងការដាក់អោយដំណើរការ កម្មវិធីកំណែទំរង់រដ្ឋបាល ក្នុងព្រំដែនសមត្ថកិច្ចរបស់ខ្លួន ។

៤ -សំរបសំរួល បណ្តាសកម្មភាពរបស់ក្រសួងនានា ដែលទាក់ទងទៅនឹងកម្មវិធីកំណែទំរង់រដ្ឋបាល ។

៥ -តាមដានការអនុវត្តនី កម្មវិធីកំណែទំរង់រដ្ឋបាល នៅតាមក្រសួង-ស្ថាប័នរដ្ឋ និង រាយការណ៍ពីលទ្ធផលទទួលបាន ជូនឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

៦ -លើកសំណើជូនឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ នូវគ្រប់គំរោងច្បាប់ លិខិតបទដ្ឋាន និងគ្រប់វិធានការចាំ[illegible] ដាក់អោយដំណើរការកំណែទំរង់រដ្ឋបាល ។

៧ -ទំនាក់[illegible] របសំរួល យកចិត្តទុកដាក់ដល់ការកេណ្ឌធនធានផ្ទាល់របស់រដ្ឋ និងជំនួយអន្តរជាតិចាំបាច់សំរាប់យកមកប្រើប្រាស់ក្នុងការដាក់អោយដំណើរការកំណែទំរង់រដ្ឋបាល ។

៨ -ផ្តល់ជូនដល់ក្រសួង-ស្ថាប័នរដ្ឋ ក្នុងព្រំដែនសមត្ថភាពរបស់ខ្លួន នូវបង្អែកបច្ចេកទេសដែលមានអត្ថប្រយោជន៍ដល់ក្រសួងទាំងអស់នោះ ពាក់ព័ន្ធនឹងកំណែទំរង់រដ្ឋបាល ។

៩- ជំរុញដឹកនាំ និងគ្រប់គ្រងការងារផ្សព្វផ្សាយពត៌មាន ស្តីពីគោលដៅសកម្មភាព និងសមិទ្ធផល នៃការងារកំណែទំរង់រដ្ឋបាល ។

មាត្រា ៤.- ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល មានសមាសភាពដូចតទៅ :

- ទេសរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន
- រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ អនុប្រធាន
- រដ្ឋលេខាធិការមួយរូប នៃទីស្តីការគណៈរដ្ឋមន្ត្រី
- និង ជា អគ្គលេខាធិការ នៃ ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល សមាជិកអចិន្ត្រៃយ៍
- រដ្ឋលេខាធិការ មុខងារសាធារណៈ សមាជិក
- រដ្ឋលេខាធិការមួយរូប នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- រដ្ឋលេខាធិការមួយរូប នៃក្រសួងមហាផ្ទៃ សមាជិក
- រដ្ឋលេខាធិការមួយរូប នៃក្រសួងអប់រំ យុវជន និង កីឡា សមាជិក
- រដ្ឋលេខាធិការមួយរូប នៃក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ សមាជិក
- រដ្ឋលេខាធិការមួយរូប នៃក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និង យុវនីតិសម្បទា សមាជិក

មាត្រា ៥.- ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល មានភារកិច្ចដូចតទៅ :

- រ៉ាប់រងបំពេញមុខការទាំងឡាយ របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ដូចមានចែងក្នុងមាត្រា ខាងលើ និងយកចិត្តទុកដាក់ធ្វើអោយដំណើរការ នៃកំណែទំរង់រដ្ឋបាល ប្រព្រឹត្តទៅប្រកបដោយ ប្រសិទ្ធភាព ។
- កំណត់របៀបវារៈ នៃការប្រជុំនានា របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។
- ដឹកនាំការពិភាក្សា និងចេញសេចក្តីសំរេចនានា ។

ប្រធានអាចអញ្ជើញសមាជិករាជរដ្ឋាភិបាល ឬ ឥស្សរជន ដែលមានគុណសម្បត្តិគ្រប់គ្រាន់ មក ចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។

ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល មានសិទ្ធិក្នុងការចុះហត្ថលេខាទ្វេភាគី និង ពហុភាគីលើ គ្រប់អនុសញ្ញានៃហិរញ្ញប្បទាន និង គ្រប់កិច្ចសន្យា ឬ អត្ថបទគតិយុត្តដែលទាក់ទងទៅនឹង កំណែទំរង់រដ្ឋបាល ។

ប្រធានមានសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រុមប្រឹក្សាកំណែ ទំរង់រដ្ឋបាល ។

មាត្រា ៦.- ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល មានសិទ្ធិលើកសំណើតែងតាំង តាមការចាំបាច់ អ្នកជំនាញការជាតិនិងអន្តរជាតិ ពើយ៉េនិងឥស្សរជន ឬមន្ត្រីរាជការជាន់ខ្ពស់ ដែលមានជំនាញក្នុងវិស័យនីតិកម្ម រដ្ឋបាល សេដ្ឋកិច្ច សង្គមកិច្ច ឬអភិបាលកិច្ច ជាទីប្រឹក្សាបច្ចេកទេស ដើម្បីសិក្សាវិភាគធ្វើទស្សនទាន ឬ ធ្វើផែនការកម្មវិធីវិស័យកំណែទម្រង់រដ្ឋបាល និងលើកសំណើជូន ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល នូវគំរោងរយៈពេលខ្លី មធ្យម និង មានរយៈពេលវែង ដែលត្រូវដាក់អោយអនុវត្ត ។

## ជំពូក ៣

## អគ្គលេខាធិការដ្ឋាន

មាត្រា ៧ .- ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល មានអគ្គលេខាធិការដ្ឋានមួយ ជាអង្គភាពប្រតិបត្តិ ដែលត្រូវបានដឹកនាំ និងគ្រប់គ្រងដោយអគ្គលេខាធិការមួយរូប ។

អគ្គលេខាធិការ មានអគ្គលេខាធិការរង និងក្រុមប្រឹក្សា ជាជំនួយការ ។ សមាជិកនៃក្រុមប្រឹក្សា និងអគ្គលេខាធិការរង ត្រូវបានតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់អគ្គលេខាធិការ ដោយមានមតិយល់ស្របពីប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

មាត្រា ៨ .- ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ត្រូវកំណត់ដោយ អនុក្រឹត្យមួយដោយឡែក ។

មាត្រា ៩ .- ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល មានសិទ្ធិប្រើប្រាស់ត្រា របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីបំពេញការងាររបស់ខ្លួន ។

## ជំពូក ៥

## ថវិកាពធនធាន

មាត្រា ១០.- ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល មានខ្ទង់ថវិកាដោយឡែក នៅក្នុងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

មាត្រា១១ .- ធនធាន និងថវិការបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលត្រូវបានផ្គត់ផ្គង់ដោយ :

-វិភាគទាន នៃថវិកាជាតិ ។

-ហិរញ្ញប្បទាន បានមកពី ប្រទេស ឬ អង្គការផ្តល់ជំនួយ អន្តរជាតិ ។

## ជំពូក ៥

## អវសានប្បញ្ញត្តិ

មាត្រា ១២.- បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៣ .- ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ស្ថាប័ន និង សមាជិកទាំងអស់ នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ត្រូវទទួលបន្ទុករៀងៗខ្លួន អនុវត្តអនុក្រឹត្យនេះដែលចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩

បានជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី
ជ.ឧត្តមក្រុមប្រឹក្សា កំណែទំរង់រដ្ឋ
សមាជិកអចិន្ត្រៃយ៍
ហត្ថលេខា
សុខ អាន

នាយករដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
ហ៊ុន សែន

★★★

អនុក្រឹត្យ លេខ ៥២ អនក្រ.បក
ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ របស់អគ្គលេខាធិការដ្ឋាន
នៃ ក្រុមប្រឹក្សា កំណែទំរង់រដ្ឋបាល

* * *

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើត ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

-បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

-តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ។